00687350

E79/2


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens



**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 05 / 2011
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun


**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំឲ្យមានការដោះលែង

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**

នួន ជា
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jaques VERGÈS
Philippe GRÉCIAN

00687351



## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះបានទទួលសំណើសុំផ្ទាល់មាត់ធ្វើឡើងដោយលោក អៀង សារី ("ជនជាប់ចោទ") នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ដោយស្នើសុំឱ្យមានការដោះលែងបណ្តោះអាសន្ន ជាដំណោះស្រាយចំពោះការឃុំខ្លួនគាត់ដោយខុសច្បាប់ និងស្នើសុំឱ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងទម្រង់នៃការឃុំខ្លួននៅក្នុងផ្ទះ ជាជម្រើសទៅនឹងការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក[១]។

## ២. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញដីកាដំណោះស្រាយ នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩/២០០៧/អ.វ.ត.ក ("សំណុំរឿង ០០២") និងបានបង្គាប់ឱ្យបន្តការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ រហូតដល់ពេលនាំខ្លួនគាត់មកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[២]។ អង្គបុរេជំនុំជម្រះ ("អបជ") បានទទួលសំណុំរឿង បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ ដែលបានដាក់ដោយក្រុមមេធាវីការពារក្តីទាំង៤ក្រុម[៣]។ ជនជាប់ចោទបានប្តឹងឧទ្ធរណ៍ដោយឡែកពីគ្នាលើសេចក្តីសម្រេចឃុំខ្លួនដែលមាននៅក្នុងដីកាដំណោះស្រាយ[៤]។

៣. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អ.ប.ជ បានចេញសាលដីកាចំនួនពីរផ្សេងគ្នាដោយគ្មានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទចំនួនពីរ ប្រឆាំងនឹងដីកាដំណោះស្រាយ

---

[១] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ៣។

[២] "ដីកាដំណោះស្រាយ" ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ") "ជំពូក៦៖ ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន"។

[៣] "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/3/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ "បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/2/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០។ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/4/3 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

[៤] "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ" ឯកសារ D427/5/1 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០។

(សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" និង "សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន") ក៏ដូចជាបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីផ្សេងទៀតដោយបង្ហាញថា សំអាងហេតុនានានឹងចេញតាមក្រោយ[៥]។ អ.ប.ជ បានបង្គាប់ឱ្យបន្តការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ អៀង សារី និងជនជាប់ចោទចំនួនបីនាក់ទៀតរហូតដល់ពេលដែលពួកគាត់ត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ នៅថ្ងៃទី ២១ និង ២៤ ខែ មករា អ.ប.ជ បានចេញសំអាងហេតុសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន និងសម្រាប់ផ្នែកស្តីពីការឃុំខ្លួននៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ដោយយល់ឃើញថា ការឃុំខ្លួនជនជាប់ចោទជាការចាំបាច់ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ដើម្បីការពារសន្តិសុខគាត់ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[៦]។ អ.ប.ជ បានផ្តល់សំអាងហេតុនានាសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពាក់ព័ន្ធនឹងជនជាប់ចោទចំនួនបីរូបក្រៅពី អៀង សារី នៅថ្ងៃទី ២១ ខែ មករា និងថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[៧]។ ជាការឆ្លើយតបទៅនឹងពាក្យសុំដោះលែងបន្ទាន់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ថា វិការៈនៅក្នុងសាលដីកាទាក់ទិននឹងដីកាដំណោះស្រាយ មិនធ្វើឱ្យគ្មានសុពលភាពដល់របៀបដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ ឬក៏មិនមានធ្វើយុត្តិកម្មសម្រាប់ការដោះលែងជនជាប់ចោទ

---

[៥] "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ៤។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ" ឯកសារ D427/5/9 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៣។

[៦] "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ" ឯកសារ D427/5/10 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ៣៥ ដល់៣៨។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន" ឯកសារ D427/1/27 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ៦ (អនុម័ត យកសំអាងហេតុដែលចេញដោយសហចៅក្រមស៊ើបអង្កេត ចំពោះការបន្តការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ១៦២៤)។

[៧] "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/4/15 ចុះថ្ងៃទី ២១ ខែ មករាឆ្នាំ ២០១១។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។

នោះដែរ[៨]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អ.ប.ជ បានចេញសំអាងហេតុសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[៩]។

៤. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៦៨(៣) នៃវិធានផ្ទៃក្នុង។ ក្នុងអំឡុងពេលសវនាការសួរដេញដោលនេះ មេធាវីការពារក្តីលោក អៀង សារី បានស្នើសុំឱ្យមានការដោះលែងជនជាប់ចោទ ដោយការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងទម្រង់នៃការឃុំខ្លួនក្នុងផ្ទះ។

## ៣. សារណា

៥. មេធាវីការពារក្តីលើកឡើងថា ថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នដែលត្រូវបានអនុញ្ញាតស្របតាមក្របខ័ណ្ឌច្បាប់ អ.វ.ត.ក មុនពេលជនជាប់ចោទត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺរយៈពេល ៣ឆ្នាំ។ ដោយសារតែលោក អៀង សារី ត្រូវបានឃុំខ្លួនដំបូងនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ គាត់ត្រូវបានឃុំខ្លួនដោយខុសច្បាប់ចាប់តាំងពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០ មក។ ហេតុដូច្នេះ ការឃុំខ្លួនជនជាប់ចោទ គឺខុសច្បាប់[១០]។ អនុលោមតាមវិធាន ៦៨(២) និង ៧៧(១៤) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីលើកឡើងថា អ.ប.ជ មានកាតព្វកិច្ចចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលមានបញ្ជាក់សំអាងហេតុ នៅក្នុងរយៈពេល ៤ខែ គិតចាប់ពីថ្ងៃចេញដីកាដំណោះស្រាយនោះ ឬថ្ងៃធ្វើបណ្តឹងឧទ្ធរណ៍។ ដោយសារតែសាលដីកាចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ មិនបានលើកសំអាងហេតុ ហេតុដូច្នេះ សាលដីកាមានវិការៈ និងដោយសារតែសំអាងហេតុទើបតែចេញនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អ.ប.ជ បានបំពានលើវិធាន ៦៨(២) នៃវិធានផ្ទៃក្នុង ដោយខកខានមិនបានចេញសាលដីកានៅក្នុងរយៈពេលកំណត់ ៤ខែ។

---

[៨] សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ឯកសារ E50 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន”) កថាខណ្ឌ៣៤-៣៥។

[៩] “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ” ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។

[១០] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ៣-៥ (ទាញសំអាងហេតុវិធានផ្ទៃក្នុង ៦៣(៦)-(៧) និង៦៨(១) ដូចទៅនឹងមាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ហេតុនេះ មេធាវីការពារក្តីស្នើសុំធ្វើមោឃភាពការឃុំខ្លួនជនជាប់ចោទដោយសារមានវិការៈផ្នែកនីតិវិធី អនុលោមតាមវិធាន ៤៨ ឬធ្វើការដោះលែងដោយដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការក្នុងទម្រង់នៃការឃុំខ្លួនក្នុងផ្ទះជាជម្រើសម្យ៉ាងទៀត[១១]។

៦. ដើម្បីគាំទ្រដល់សំណើសុំដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មេធាវីការពារក្តីលើកឡើងថា ខ្លួនបានធ្វើការទំនាក់ទំនងជាដំបូងជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ ២០០៨ ពាក់ព័ន្ធនឹងភាពអាចធ្វើបាននៃការឃុំខ្លួនក្នុងផ្ទះ ដែលបានបង្ហាញថា វិធានការណាមួយពាក់ព័ន្ធនឹងជនជាប់ចោទស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ អ.វ.ត.ក[១២]។ មេធាវីការពារក្តីលើកឡើងថែមទៀតថា ក្នុងករណីអង្គជំនុំជម្រះសាលាដំបូងយល់ព្រមឱ្យមានការឃុំខ្លួនក្នុងផ្ទះ រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់សន្តិសុខ សុវត្ថិភាព និងការធ្វើដំណើរពីភ្នំពេញទៅ អ.វ.ត.ក ដោយសហការជាមួយអង្គជំនុំជម្រះសាលាដំបូង[១៣]។

៧. សហព្រះរាជអាជ្ញាជំទាស់នឹងសំណើសុំ។ ថិរវេលាអតិបរមានៃការឃុំខ្លួន ចំនួន ៣ឆ្នាំ ស្របតាមវិធាន ៦៣ នៃវិធានផ្ទៃក្នុង អនុវត្តតែចំពោះរយៈពេលមុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ វាបន្តពីវិធាន ៦៨(៣) នៃវិធានផ្ទៃក្នុង ដែលចែងថា រយៈពេលឃុំខ្លួន ៤ខែបន្ថែមទៀត ចាប់ផ្តើមនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ដែលបានកើតឡើងនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[១៤]។ ព្រះរាជអាជ្ញាលើកឡើងថែមទៀតថា ការបន្តការឃុំខ្លួនបណ្តោះអាសន្នជាការត្រឹមត្រូវ អនុលោមតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង។ បន្ទាប់ពីការចេញដីកាដំណោះស្រាយ មានមូលហេតុសមស្របដែលនាំឱ្យជឿបានថាជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋដែលខ្លួនត្រូវបានចោទប្រកាន់។ ការឃុំខ្លួនក៏ជាការចាំបាច់ផងដែរដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ។ ដោយសារតែជនជាប់ចោទត្រូវ

---

[១១] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ៤-១០, ១២ (ដោយលើកឡើងថា មូលហេតុដែលបានចេញនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ គឺជាសាលដីកាថ្មីមួយ ជាអាទិ៍។

[១២] *សូមមើល* លិខិតរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជំរាបមកមេធាវីការពារក្តី អៀង សារី ឯកសារ E79/1.1 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ (ដែលបានដាក់បន្ទាប់ពីសវនាការដេញដោល)។

[១៣] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ២០-២៤។

[១៤] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ១៣-១៩ (កត់សម្គាល់ថែមទៀតពីកង្វះពេលវេលារបស់ជនជាប់ចោទ ក្នុងការលើកឡើងពីអនីត្យានុកូលភាពនៃការឃុំខ្លួន ដែលត្រូវបានជំទាស់ដោយជនជាប់ចោទ ចំនួន ៣នាក់ទៀត ដោយផ្អែកលើមូលដ្ឋានស្រដៀងគ្នានៅខែ មករា ឆ្នាំ ២០១១ (*សូមមើល* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន កថាខណ្ឌ៩, ១១)។

បានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត ដែលត្រូវទទួលទោសធ្ងន់ធ្ងរក្នុងករណីមានការផ្តន្ទាទោសនោះ ជនជាប់ចោទពិតជាមានគំនិតចង់គេចខ្លួន។ របាយការណ៍ព័ត៌មានផ្សេងៗនៅក្នុងសំណុំរឿងបញ្ជាក់ពីលទ្ធភាព និងបំណងចង់ចាកចេញពីប្រទេសរបស់ជនជាប់ចោទ ដូចដែលបានបង្ហាញតាមរយៈប្រភពសម្ភារៈនានា និងការធ្វើដំណើរទៅបរទេសជាញឹកញាប់កាលពីអតីតកាលរបស់ជនជាប់ចោទ។ ជនជាប់ចោទក៏មានទំនាក់ទំនងដ៏មានឥទ្ធិពលនៅតំបន់ព្រំដែនផងដែរ។ ជនជាប់ចោទមានលិខិតឆ្លងដែនសញ្ជាតិខ្មែរផង និងលិខិតឆ្លងដែនសញ្ជាតិចិនដែលធ្វើឡើងក្រោមអត្តសញ្ញាណក្លែងក្លាយផង។ លើសពីនេះទៀត សេចក្តីថ្លែងការណ៍មុនៗបង្ហាញឱ្យឃើញពីកង្វះកិច្ចសហការរបស់ជនជាប់ចោទជាមួយ អ.វ.ត.ក។ មេធាវីការពារក្តីក៏មិនបានបង្ហាញភស្តុតាងឱ្យឃើញថា ការឃុំខ្លួនក្នុងផ្ទះជាការសមស្របនោះដែរ[១៥]។

៨. មេធាវីការពារក្តីជំទាស់ថា លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នដែលមាននៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង មិនត្រូវបានបំពេញនោះទេ។ លិខិតឆ្លងដែនសញ្ជាតិចិនគឺចុះកាលបរិច្ឆេទពីឆ្នាំ ១៩៧៩។ ទោះបីជាកត់សម្គាល់ឃើញថា ព័ត៌មានដែលបានដកស្រង់ដោយព្រះរាជអាជ្ញាច្រើនតែជាព័ត៌មានចចាមអារ៉ាមក៏ដោយ ក៏មេធាវីការពារក្តីមិនជំទាស់នឹងការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា ជនជាប់ចោទមានមធ្យោបាយគ្រប់គ្រាន់នោះដែរ។ ពីមុនជនជាប់ចោទបានធ្វើដំណើរទៅប្រទេសថៃដើម្បីព្យាបាលជំងឺ តែពេលនេះគាត់ពុំចាំបាច់ធ្វើដូច្នេះតទៅទៀតទេ ដោយសារតែមានការថែទាំសុខភាព "ដ៏ប្រសើរ" ដែលផ្តល់ ដោយ អ.វ.ត.ក[១៦]។ លើសពីនេះទៀត មេធាវីការពារក្តីបានតវ៉ាថា ទ្រព្យសម្បត្តិដែលបានលើកឡើងរបស់ជនជាប់ចោទ បានបង្ហាញប្រហែលគ្នាថា ជនជាប់ចោទអាចចាកចេញពីប្រទេសមុនពេលចាប់ខ្លួន ប្រសិនបើគាត់មានចេតនាធ្វើដូច្នេះមែននោះ។ ក្នុងករណីណាក៏ដោយ មេធាវីការពារក្តីលើកឡើងថា ការឃុំខ្លួនក្នុងផ្ទះអាចធ្វើបានដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ និងជាការការពារគ្រប់គ្រាន់ប្រឆាំងនឹងហានិភ័យនៃការគេចខ្លួន[១៧]។

---

[១៥] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ២៤-២៦, ៣០-៣៤។

[១៦] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ៣៥។

[១៧] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ៩-១០, ៣៤-៣៧។

## ៥. សំអាងហេតុ

៩. អនុលោមតាមវិធាន ៨២(២) នៃវិធានផ្ទៃក្នុង "គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទ ឬដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទបាន ស្របតាមវិធានផ្ទៃក្នុងនេះ"។ នៅក្នុងសំណើរបស់មេធាវីការពារក្តីនេះ មានសំណើចំនួន ២ ជាចម្បង។ សំណើទីមួយគឺសំណើសុំដោះលែងជនជាប់ចោទ ដោយសារមេធាវីយល់ថា ជនជាប់ចោទត្រូវបានឃុំខ្លួនដោយខុសច្បាប់ រីឯ សំណើទីពីរគឺ សុំដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងទម្រង់ជាការឃុំខ្លួននៅក្នុងផ្ទះ។

<u>១. សំណើសុំដោះលែង (មានការចោទប្រកាន់អំពីភាពពុំស្របច្បាប់នៃការឃុំខ្លួនជនជាប់ចោទ)</u>

*ក. ថិរវេលាអតិបរមានៃការឃុំខ្លួន (មានការចោទប្រកាន់អំពីការឃុំខ្លួនដោយខុសច្បាប់)*

១០. មេធាវីការពារក្តីចោទថា វិធាន ៦៣(៦) និង(៧) ពេលអានរួមគ្នាជាមួយវិធាន ៦៨(១) និងមាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បង្កើតបានជារយៈពេលកំណត់ដាច់ខាតមួយក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចំនួន៣ឆ្នាំ លើកលែងតែមានការនាំខ្លួនជនជាប់ចោទមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលនោះ។ អង្គជំនុំជម្រះយល់ឃើញថា ការលើកយកក្រមនីតិវិធីព្រហ្មទណ្ឌមកធ្វើជាសំអាង ពុំមានភាពចាំបាច់ឡើយបើយើងគិតទៅលើចំណុចដែលថា វិធាន ៦៣(៦) និង(៧) ដែលត្រូវយកមកអានផ្ទួបគ្នាជាមួយវិធាន៦៨(១) និង(៣) ចែងថា នៅពេលមានដីកាដំណោះស្រាយ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នអាចបន្តចំនួន៤ខែទៀត។ រយៈពេលនៃការបន្តឃុំខ្លួនជនជាប់ចោទចំនួន ៤ ខែនេះពុំពាក់ព័ន្ធនឹងពេលកំណត់ក្នុងការឃុំខ្លួនជាអតិបរមាចំនួន ៣ឆ្នាំ ដូចដែលមានចែងនៅក្នុងវិធាន ៦៣(៦) និង(៧) ឡើយ ហើយអង្គបុរេជំនុំជម្រះអាចសម្រេចបន្តឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នចំនួន៤ខែបន្ថែមទៀត ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទក្នុងរយៈពេល៤ខែនេះ បន្ទាប់ពីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នបន្ថែមចំនួន៤ខែ ចាប់គិតពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ តទៅ (ដែលជាថ្ងៃបរិច្ឆេទដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលការជូនដំណឹងអំពីសាលដីកាលើដីកាដំណោះស្រាយ និងជាថ្ងៃដែល អ.ជ.ស.ដ បានទទួលសំណុំរឿងនេះ)។ អនុលោមតាមវិធាន ៨២(១) រយៈពេល

ឃុំខ្លួនចំនួន៤ខែនេះ ពុំទាន់បានផុតកំណត់នៅឡើយទេ គិតត្រឹមថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ ដែលជាថ្ងៃនាំខ្លួនជនជាប់ចោទមកចំពោះមុខអង្គជំនុំជម្រះ។

*ខ. ការខ្វះសំអាងហេតុ (មានការចោទប្រកាន់អំពីការរំលោភលើវិធាន ៦៨(២))*

១១. ពាក់ព័ន្ធនឹងជនជាប់ចោទ៣រូបទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា នៅក្នុងសំណុំរឿង ០០២ ខ្លួនបានទទួលសំណុំរឿងនេះដោយត្រឹមត្រូវ ទោះបីជាសាលដីការបស់អង្គបុរេ-ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយមានវិការៈមួយចំនួនក្តី[១៨]។ ទោះបីក្រោយពេល អ.ប.ជ ចេញសាលដីកានេះបានចំនួន ៨៨ ថ្ងៃ ទើប អ.ប.ជ ចេញសំអាងហេតុតាមក្រោយក្តី[១៩] ក៏អង្គជំនុំជម្រះយល់ឃើញថា ចំណុចនេះពុំប៉ះពាល់ដល់ការសម្រេចរបស់ខ្លួនឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួនបានទទួលដោយត្រឹមត្រូវនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទទាំងអស់ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១[២០]។

១២. អង្គជំនុំជម្រះសូមរំឭកថា ពាក់ព័ន្ធនឹងជនជាប់ចោទ ៣ រូបផ្សេងទៀត កាលពីពេលកន្លងទៅថ្មីៗ អង្គជំនុំជម្រះបានសម្រេចថា ទោះបីជាបែបណាក៏ដោយ ការយឺតយ៉ាវរបស់ អ.ប.ជ ក្នុងការចេញសំអាងហេតុទៅលើសាលដីការបស់ខ្លួន បង្កើតបានជាវិការៈនីតិវិធី ដោយបានរំលោភទៅលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[២១]។ ដូច្នេះ អ.ជ.ស.ដ យល់ឃើញថា សិទ្ធិរបស់ អៀង សារី ត្រូវបានរំលោភ

---

[១៨] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន កថាខណ្ឌ ៣០-៣៥, ៤៣ (ដោយបានតម្កល់ភាពស្របច្បាប់នៃការឃុំខ្លួន ខៀវ សំផន, អៀង ធីរិទ្ធ និង នួន ជា និងដោយបានកត់សម្គាល់ថាវិការៈនេះត្រូវបានផ្តល់សំណងរួចហើយ នៅពេលអង្គជំនុំជម្រះបានយកបញ្ហានេះមកពិចារណា)។ សំអាងហេតុដែលបានចេញក្រោយពេលមានសាលដីកាចំនួន ០៨ ថ្ងៃ ពាក់ព័ន្ធនឹង ខៀវ សំផន និង៣២ ថ្ងៃ ក្រោយពេលមានសាលដីកាពាក់ព័ន្ធនឹង អៀង ធីរិទ្ធ និង នួន ជា។

[១៩] ខណៈដែលអង្គបុរេជំនុំជម្រះបានចេញឯកសារពីរចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ និង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ក្រោមចំណងជើងដូចគ្នាគឺ "ដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" (D427/1/26 និង D427/1/30), វាច្បាស់ណាស់ថាឯកសារមុនមិននាំឱ្យមានសេចក្តីសម្រេចថ្មីមួយដូចរៀបរាប់ខាងលើទេ ប៉ុន្តែគ្រាន់តែមានសំអាងហេតុនៃសេចក្តីសម្រេចតែមួយដែលបានចេញជាចម្បងក្នុងទិសដៅថា "សំអាងហេតុ [ត្រូវ] ធ្វើទៅតាមពេលវេលាសមស្រប"។

[២០] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន, កថាខណ្ឌ ៣៤ និង ៤៣។

[២១] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន, កថាខណ្ឌ ២៩-៣០,៣៤ (ទាក់ទងនឹងជនជាប់ចោទបីរូបទៀត សូមកត់សម្គាល់ថាការបំពារបំពាននេះត្រូវបានដោះស្រាយតាមរយៈការចេញសំអាងហេតុដ៏ពេញលេញជាបន្តបន្ទាប់ នៅពេលមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន។

តាមរយៈការឃើញយ៉ាងក្នុងការចេញសំអាងហេតុទៅលើសាលដីកាលើដីកាដំណោះស្រាយ និងផ្នែកស្តីពីការឃុំខ្លួនក្នុងសាលដីកានោះ ក៏ដូចជាសាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួន[២២]។ ទោះបីនៅក្នុងសំណុំរឿងមួយនេះ ការរំលោភសិទ្ធិរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងសាលដីកាលើដីកាដំណោះស្រាយ នៅតែបានបន្តកើតមានយូរជាងសំណុំរឿងជនជាប់ចោទផ្សេងទៀតក្តី ក៏អង្គជំនុំជម្រះយល់ឃើញថា ការដោះលែងគាត់ជាបន្ទាន់ពុំមែនជាសំណងមួយសមស្របឡើយ។ អង្គជំនុំជម្រះអាចពិចារណាទៅលើសំណងសមស្របនានាចំពោះការរំលោភសិទ្ធិរបស់ អៀង សារី នៅពេលបញ្ចប់ការជំនុំជម្រះ គឺនៅក្រោយពេលស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីនានារួច។

*គ. លក្ខខណ្ឌនៃការឃុំខ្លួន អនុលោមតាមវិធាន ៦៣(៣)*

១៣. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាតើការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន មានហេតុផលត្រឹមត្រូវដែរ ឬទេ អនុលោមតាមលក្ខខណ្ឌនានាដែលមានចែងនៅក្នុងវិធាន ៦៣(៣)។ អ.ជ.ស.ដ យល់ថា មានហេតុផលគ្រប់គ្រាន់ក្នុងការជឿថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ អនុលោមតាមវិធាន ៦៣(៣)(ក) ក្រោយពីមានដីកាដំណោះស្រាយ និងមានការបញ្ជាក់គាំទ្ររបស់ អ.ប.ជ ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញទៀតថា ភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានចោទប្រកាន់មកលើជន-ជាប់ចោទ និងទោសជាធរមាននៅពេលមានការផ្តន្ទាទោស បង្កើតឱ្យមានហានិភ័យខ្ពស់ក្នុងការរត់គេចខ្លួន ប្រសិនបើជនជាប់ចោទត្រូវបានតុលាការដោះលែង។ ដូច្នេះ មានមូលដ្ឋានគ្រប់គ្រាន់ក្នុងការឃុំខ្លួនជនជាប់ចោទ អនុលោមតាមវិធាន ៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង។

## <u>២. សំណើសុំដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (ការឃុំខ្លួននៅក្នុងផ្ទះ)</u>

១៤. ទោះបីក្រុមមេធាវីការពារក្តីពុំសូវមានអំណះអំណាងជាក់ស្តែង ដើម្បីលើកយកមកធ្វើជាបង្អែកដល់សំណើសុំដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្តី ក៏អង្គជំនុំ-ជម្រះបានលើកយកព័ត៌មាននានាដែលបានលើកឡើង កាលពីពេលសវនាការមកពិចារណាផងដែរ ពាក់ព័ន្ធទៅនឹងជម្រើសសមស្របក្រៅពីការឃុំខ្លួន ពិសេសគឺលទ្ធភាព និងភាពសមស្រប

---

[២២] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឃុំខ្លួន, កថាខណ្ឌ ៣៦។ សំអាងហេតុសម្រាប់ការឃុំខ្លួន ជនជាប់ចោទត្រូវបានចេញនៅថ្ងៃទី ២១ ខែ មករា នៅថ្ងៃតែមួយជាមួយជនជាប់ចោទផ្សេងទៀត។

នៃជម្រើសឃុំខ្លួននៅក្នុងផ្ទះ។ ត្រង់ចំណុចនេះ លិខិតមួយច្បាប់របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៨ (ឯកសារលេខ E79/1.1) ដែលក្រុមមេធាវីការពារក្តីបានដាក់ក្នុងអំឡុងពេលនៃកិច្ចសវនាការ ពុំបានជួយអ្វីដល់អង្គជំនុំជម្រះជាដុំកំភួនឡើយ។ នៅក្នុងអំឡុងពេលនៃកិច្ចសវនាការ ក្រុមមេធាវីការពារក្តីបានត្រឹមតែសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា ឬ អ.វ.ត.ក នឹងអាចជួយផ្តល់ការការពារសន្តិសុខ និងការដឹកជញ្ជូន ក៏ដូចជាការថែទាំវេជ្ជសាស្ត្រដល់ជនជាប់ចោទ ប្រសិនបើពុំមានការឃុំខ្លួនជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក នោះ។ ក្រុមមេធាវីការពារក្តីពុំបានរៀបរាប់លម្អិតឡើយ អំពីទីតាំងពិតប្រាកដនៃផ្ទះដែលត្រូវដាក់ជនជាប់ចោទ ឬការធានាណាមួយដែលថាជនជាប់ចោទនឹងគោរពដីកាកោះហៅឱ្យចូលបង្ហាញខ្លួននៅតុលាការ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការបន្តឃុំខ្លួនជនជាប់ចោទនៅ អ.វ.ត.ក មានភាពចាំបាច់ដើម្បីធានាថាជនជាប់ចោទមានវត្តមានក្នុងអំឡុងពេលជំនុំជម្រះតាមនីតិវិធី និងដើម្បីការពារហានិភ័យក្នុងការរត់គេចខ្លួនរបស់ជនជាប់ចោទ។ ដូច្នេះ អ.ជ.ស.ដ បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ ដោយអនុលោមតាមវិធាន ៦៣(៣)(ខ)(iii)។

## តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង

**រកឃើញថា** ការយឺតយ៉ាវរបស់ អ.ប.ជ ក្នុងការចេញសំអាងហេតុទៅលើសាលដីកាលើដីកាដំណោះស្រាយ និងទៅលើផ្នែកស្តីពីការឃុំខ្លួននៅក្នុងសាលដីកាលើដីកាដំណោះស្រាយ ក៏ដូចជាសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន គឺបានបណ្តាលឱ្យមានការរំលោភសិទ្ធិរបស់ជនជាប់ចោទ។

**ប្រកាសថា** ប្រភេទនៃសំណងចំពោះការរំលោភសិទ្ធិនេះ អាចនឹងពិចារណានៅពេលបញ្ចប់ការជំនុំ-ជម្រះ ពោលគឺបន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីលើបញ្ហានេះ។

**បដិសេធ** សំណើសុំដោះលែងរបស់ជនជាប់ចោទ។

**បដិសេធ** សំណើសុំដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងទម្រង់ជាការឃុំខ្លួននៅក្នុងផ្ទះ។

**កត់សម្គាល់ថា** ជនជាប់ចោទត្រូវបាននាំខ្លួនមកចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៦៨(៣) និងវិធាន ៨២ (១) ហើយជនជាប់ចោទត្រូវជាប់ឃុំជាបន្តរហូតដល់ថ្ងៃដែលអង្គជំនុំជម្រះប្រកាស

សាលក្រម លើកលែងតែមានការដាក់សំណើសុំដោះលែងជាថ្មី អនុលោមតាមវិធាន ៨២(៤) នៃវិធានផ្ទៃក្នុង។

ភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន